# 「農業技能測定試験」試験実施要領　クメール語版

# គោលការណ៍ណែនាំអំពីការអនុវត្ត “ការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញកសិកម្ម” ជាភាសាខ្មែរ

2019 年 9 月

ជាខែកញ្ញាឆ្នាំ2019

នីតិបុគ្គលសមាគមរួមបញ្ចូលទូទៅ សភាកសិកម្មជាតិ

ដើម្បីធានាបាននូវការអនុវត្តត្រឹមត្រូវនៃការប្រឡងសមត្ថភាពជំនាញដែលទាក់ទងនឹងជំនាញជាក់លាក់ប្រភេទ1នៃផ្នែកកសិកម្ម(តទៅហៅថា “ការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញកសិកម្ម”) គោលការណ៍ណែនាំអំពីការអនុវត្ត “ការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញកសិកម្ម” ត្រូវបានកំណត់ដូចតទៅនេះ ដោយអនុលោមតាម “អំពីគោលការណ៍នៃការប្រឡងពាក់ព័ន្ធនឹង “ជំនាញជាក់លាក់” ” (ខែកុម្ភៈឆ្នាំ2019 ដោយនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងយុត្តិធម៌) (តទៅហៅថា “គោលការណ៍ប្រឡង”) ដែលត្រូវបានកំណត់ផ្អែកតាម “គោលការណ៍មូលដ្ឋានពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធដែលទាក់ទងនឹងទិដ្ឋាការនៃជំនាញជាក់លាក់” (សម្រេចដោយអង្គប្រជុំគណៈរដ្ឋមន្ត្រីថ្ងៃទី25ខែធ្នូឆ្នាំ2018) ចំណុចទី3 (1) ង និង (2) គ។

## 1　ខ្លឹមសារសង្ខេបនៃការប្រឡង

### （1）ស្ថាប័នអនុវត្ត

នីតិបុគ្គលសមាគមរួមបញ្ចូលទូទៅ សភាកសិកម្មជាតិ( តទៅហៅថា “សភាកសិកម្មជាតិ")

（2）ភាសាប្រើក្នុងការប្រឡង

ជាមូលដ្ឋានគឺភាសារបស់ប្រទេសដែលអនុវត្តការប្រឡងព្រមទាំងភាសាអង់គ្លេស ហើយចំពោះសំណួរដើម្បីត្រួតពិនិត្យសមត្ថភាពភាសាជប៉ុនដែលចាំបាច់ក្នុងការបំពេញការងារគឺប្រើភាសាជប៉ុន។

（3）វិធីសាស្ត្រអនុវត្ត

ទម្រង់តេស្តផ្អែកលើកុំព្យូទ័រ( Computer Based Testing ឬCBT )។

( សំគាល់ ) ជាទម្រង់សួរនិងឆ្លើយដោយប្រើកុំព្យូទ័រនៅមណ្ឌលប្រឡង ហេតុនេះបេក្ខជនប្រឡងត្រូវឆ្លើយនៅលើផ្ទាំងអេក្រង់ទៅតាមសំណួរដែលបង្ហាញលើអេក្រង់កុំព្យូទ័រនិងសំឡេងបន្លឺតាមកាសត្រចៀកនៅតុប្រឡង។

（4）ចំនួនដងនៃការអនុវត្ត ពេលវេលាអនុវត្ត និងទីតាំងអនុវត្តសម្រាប់ឆ្នាំការងារ

ការអនុវត្តនៅក្រៅប្រទេសជប៉ុនក្នុងឆ្នាំ2019 គឺក្នុងចំណោមប្រទេសខាងក្រោមដែលមានការរៀបចំឲ្យអាចអនុវត្តតេស្តមូលដ្ឋានភាសាជប៉ុនមូលនិធិប្រទេសជប៉ុន( តទៅហៅថា “តេស្តមូលដ្ឋានភាសាជប៉ុន”) ដែលអនុវត្តដោយនីតិបុគ្គលរដ្ឋបាលឯករាជ្យមូលនិធិប្រទេសជប៉ុន( តទៅហៅថា “មូលនិធិប្រទេស

ជប៉ុន")។

- ជាគោលការណ៍គឺចាប់ផ្តើមការប្រឡងចាប់ពីថ្ងៃដូចគ្នានិងនៅទីក្រុងដូចគ្នានឹងតេស្តមូលដ្ឋានភាសាជប៉ុនដែលមូលនិធិប្រទេសជប៉ុនគ្រោងអនុវត្ត នៅអំឡុងចុងខែតុលាដល់ពាក់កណ្តាលខែវិច្ឆិកាឆ្នាំ2019។

 ① ហ្វីលីពីន

- ជាគោលការណ៍គឺចាប់ផ្តើមការប្រឡងចាប់ពីថ្ងៃដូចគ្នានិងនៅទីក្រុងដូចគ្នានឹងតេស្តមូលដ្ឋានភាសាជប៉ុនដែលមូលនិធិប្រទេសជប៉ុនគ្រោងអនុវត្ត នៅខែមករាឬខែមិនាឆ្នាំ2020 ។

 ①ចិន

 ②វៀតណាម

 ③ឥណ្ឌូនេស៊ី

 ④កម្ពុជា

 ⑤ថៃ

 ⑥មីយ៉ាន់ម៉ា

ចំពោះចំនួនដងនៃការអនុវត្ត ពេលវេលាអនុវត្ត និងទីតាំងអនុវត្តនៅក្នុងប្រទេសជប៉ុនសម្រាប់ឆ្នាំ2019 គឺសភាកសិកម្មជាតិធ្វើការកំណត់ដោយសម្របសម្រួល

ជាមួយក្រសួងកសិកម្ម។

ចំពោះចំនួនដងនៃការអនុវត្ត ពេលវេលាអនុវត្ត និងទីតាំងអនុវត្តសម្រាប់ឆ្នាំ2020 ទៅ គឺសភាកសិកម្មជាតិធ្វើការកំណត់ដោយសម្របសម្រួលជាមួយក្រសួងកសិកម្ម។

（5）អ្នកមានសិទ្ធិប្រឡង

មានអាយុចាប់ពី17ឆ្នាំពេញឡើងទៅគិតត្រឹមថ្ងៃប្រឡង។ យ៉ាងណាមិញ អ្នកដែលប្រឡងនៅក្នុងប្រទេសជប៉ុន ត្រូវបំពេញលក្ខខណ្ឌទាំងអស់ពី ក ដល់ គ ដូចខាងក្រោម។

ក　ជាអ្នកស្នាក់នៅរយៈពេលមធ្យមនិងវែង(ជាអ្នកដែលត្រូវបានកំណត់ក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍និងការទទួលស្គាល់ជនភៀសខ្លួនមាត្រា19កថាខណ្ឌទី3 ដោយលើកលែង អ្នកដែលត្រូវបានការអនុញ្ញាតរយៈពេលស្នាក់មិនលើស“3ខែ” អ្នកដែលត្រូវបានផ្តល់ទិដ្ឋាការប្រភេទណាមួយក្នុងចំណោម “ស្នាក់នៅរយៈពេលខ្លី” “ការទូត” “មន្ត្រីផ្លូវការ” អ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេសនិងអ្នកដែលគ្មានទិដ្ឋាការជាដើម) ឬអ្នកដែលធ្លាប់ស្នាក់នៅក្នុងនាមជាអ្នកស្នាក់នៅរយៈពេលមធ្យមនិងវែងកាលពីអតីតកាល។

ខ　មានលិខិតឆ្លងដែនដែលចេញដោយរដ្ឋាភិបាលបរទេសឬស្ថាប័នមាន

សមត្ថកិច្ចក្នុងតំបន់ដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌កំណត់ក្នុងប្រកាស ក្នុងនាមជាសហការយ៉ាងរលូនក្នុងការអនុវត្តបទបញ្ជាបង្ខំឲ្យចាកចេញពីប្រទេស។

គ មិនត្រូវលក្ខខណ្ឌណាមួយដូចខាងក្រោម។

① សិស្សបរទេសដែលបោះបង់ការសិក្សាឬត្រូវបានបណ្តេញពីសាលា

② សិក្ខាកាមហ្វឹកហ្វឺនជំនាញដែលបានបាត់ខ្លួន

③ អ្នកដែលស្នាក់នៅដោយទិដ្ឋាការ "សកម្មភាពជាក់លាក់(ស្នើសុំជាជនភៀសខ្លួន)"

④ អ្នកដែលពិតជាកំពុងធ្វើសកម្មភាពដោយទិដ្ឋាការដែលទាមទារឲ្យបង្កើតផែនការក្នុងការអនុវត្តសកម្មភាពរួមទាំងការហ្វឹកហ្វឺនជំនាញ(តទៅហៅថា "ផែនការសកម្មភាព") (មិនមានគម្រោងផ្លាស់ប្តូរប្រភេទទិដ្ឋាការដោយគិតលើលក្ខណៈនៃផែនការនោះ ឬមានគម្រោងផ្លាស់ប្តូរប្រភេទទិដ្ឋាការឬពន្យាររយៈពេលស្នាក់នៅបន្ទាប់ពីបញ្ចប់សកម្មភាពនោះស្របតាមផែនការនោះ)។ជាក់ស្តែង គឺអ្នកដែលកំពុងធ្វើសកម្មភាពផ្អែកតាមផែនការសកម្មភាពទាក់ទងនឹងទិដ្ឋាការដូចខាងក្រោម

・"ហ្វឹកហ្វឺនជំនាញ"

・"ហ្វឹកហាត់ការងារ"

・"សកម្មភាពជាក់លាក់(គម្រោងបណ្តុះបណ្តាលធនធានមនុស្សដើម្បីពង្រីកអាហារជប៉ុនទៅបរទេស)"

・"សកម្មភាពជាក់លាក់(គម្រោងពង្រីកអាហារប្រពៃណីជាក់លាក់ទៅបរទេស)"

・“សកម្មភាពជាក់លាក់(គម្រោងជំរុញការទទួលយកបុគ្គលិកបរទេសក្នុងវិស័យផលិតកម្ម)”

・“សកម្មភាពជាក់លាក់(ហាត់ការការងារ)”

・“សកម្មភាពជាក់លាក់(គម្រោងជំរុញសកម្មភាពបង្កើតអាជីវកម្មរបស់ជនបរទេស)”

・“គ្រប់គ្រងអាជីវកម្ម ការគ្រប់គ្រង(គម្រោងជំរុញការទទួលយកធនធានមនុស្សបង្កើតអាជីវកម្មសម្រាប់ជនបរទេស)”

（6） ចំណុចត្រូវប្រុងប្រយ័ត្ននៅពេលអនុវត្តការប្រឡង

ក　ចំណុចចាំបាច់នៅក្នុងការដាក់ពាក្យប្រឡងដូចជា ថ្ងៃប្រឡង មណ្ឌលប្រឡង រយៈពេលកក់ការប្រឡង តម្លៃចូលប្រឡងនិងវិធីបង់ប្រាក់ជាដើម គឺមានការផ្សព្វផ្សាយក្នុងគេហទំព័រសម្រាប់ប្រឡងដែលគ្រប់គ្រងដោយភ្នាក់ងារដែលទទួលអនុវត្តការប្រឡងដូចមានក្នុងចំណុច2(2)ខាងក្រោម (តទៅហៅថា “គេហទំព័រប្រឡង”)។ ការដាក់ពាក្យប្រឡងជាគោលការណ៍គឺត្រូវអនុវត្តតាមរយៈការកក់ការប្រឡងនៅលើគេហទំព័រប្រឡង។

ខ　ក្នុងការអនុវត្តការប្រឡងនៅបរទេស ត្រូវអនុវត្តដោយគោរពតាមច្បាប់បទប្បញ្ញត្តិនិងបទបញ្ជាពាក់ព័ន្ធរបស់ប្រទេសនោះ។

（7） វិធីជូនដំណឹងជាប់ធ្លាក់

ក្រោយចប់ការអនុវត្តការប្រឡង ក្នុងរង្វង់ពេល5ថ្ងៃធ្វើការ បេក្ខជនប្រឡងអាចទទួលបានរបាយការណ៍ពិន្ទុដែលមាន ឈ្មោះបេក្ខជន ឈ្មោះការប្រឡង ថ្ងៃប្រឡង រូបថតមុខ ពិន្ទុសរុប លទ្ធផលជាប់ធ្លាក់ជាដើម។

2　ប្រព័ន្ធអនុវត្តការប្រឡង

（1）ប្រព័ន្ធបង្កើតសំណួរប្រឡង

ដើម្បីបង្កើតសំណួរប្រឡង សភាកសិកម្មជាតិនឹងបង្កើតក្រុមប្រឹក្សាភិបាលអ្នកជំនាញដោយរួមផ្សំពីអ្នកជំនាញខាងគ្រប់គ្រងកសិកម្មនិងបច្ចេកទេសកសិកម្ម ការអប់រំថ្នាក់ឧត្តមសិក្សាជាដើម(តទៅហៅថា “ក្រុមប្រឹក្សាភិបាល”) ព្រមទាំងបង្កើតគណៈកម្មការឯកទេសផ្នែកកសិកម្មដាំដំណាំនិងកសិកម្មចិញ្ចឹមសត្វ និងភាសាជប៉ុន។

គណៈកម្មការឯកទេសនឹងបង្កើតសំណើព្រាងនៃសំណួរប្រឡងផ្អែកតាមខ្លឹមសារដែលកំណត់ក្នុងគោលការណ៍ណែនាំនេះចំណុចទី3ដល់ទី5 ហើយបន្ទាប់ពីទទួលការពិនិត្យបញ្ជាក់ពីក្រុមប្រឹក្សាភិបាល នឹងកំណត់សម្រេចសំណួរប្រឡង។

（2）ប្រព័ន្ធអនុវត្តការប្រឡង

ការងារពាក់ព័ន្ធនឹងការអនុវត្តការប្រឡងដោយទម្រង់CBTនិងនៅបរទេស នឹងត្រូវពឹងឲ្យភ្នាក់ងារដែលផ្តល់សេវាកម្មCBTជាអ្នកអនុវត្ត(តទៅហៅថា “ភ្នាក់ងារCBT”)។ ភ្នាក់ងារនេះនឹងអនុវត្តការងារពាក់ព័ន្ធនឹងការប្រឡងដែលរួមមាន ការ

រៀបចំមណ្ឌលប្រឡង ការរៀបចំបុគ្គលិកនៅមណ្ឌលប្រឡងដូចជាអនុរក្សជាដើម ការទទួលការកក់ការប្រឡង ការគ្រប់គ្រងមណ្ឌលប្រឡងក្នុងថ្ងៃប្រឡង(រួមទាំងបញ្ជាក់អត្តសញ្ញាណបេក្ខជនប្រឡង) ការបញ្ជូនសំណួរប្រឡងជាដើម។

（3） ប្រព័ន្ធតាមដានការអនុវត្តការប្រឡងត្រឹមត្រូវ

・សភាកសិកម្មជាតិ ក្រោយបញ្ចប់ការអនុវត្តការប្រឡង ត្រូវធ្វើរបាយការណ៍អំពីស្ថានភាពអនុវត្តការប្រឡងទៅក្រសួងកសិកម្ម និងទទួលការណែនាំនិងដឹកនាំបើសិនចាំបាច់។

・សភាកសិកម្មជាតិ ត្រូវអនុវត្តការពិនិត្យបញ្ជាក់ប្រសិទ្ធភាពការងារតាមលទ្ធផលការប្រឡងនិងស្ថានភាពអនុវត្តការងារប្រមាណ1ដងក្នុងមួយឆ្នាំនៅក្រុមប្រឹក្សាភិបាល។

・សភាកសិកម្មជាតិ អាចចាត់វិធានការចំពោះបេក្ខជនដែលបានប្រព្រឹត្តខុសឆ្គង ដោយចាត់ទុកលទ្ធផលប្រឡង(រួមទាំងលទ្ធផលពីអតីតកាល)ជាមោឃៈ។

3　កម្រិតនៃការប្រឡង

កម្រិតជាប់ប្រហែល7ភាគចំពោះអ្នកដែលមានបទពិសោធន៍ការងារនៅប្រទេសជប៉ុន3ឆ្នាំឡើង (កម្រិតសមមូលនឹងការប្រឡងវាយតម្លៃការហ្វឹកហ្វឺនជំនាញកសិកម្ម(កម្រិតឯកទេស)នៅក្នុងការហ្វឹកហ្វឺនជំនាញកសិកម្មដាំដំណាំនិងកសិកម្មចិញ្ចឹមសត្វ)

4 មុខវិជ្ជាប្រឡង

ការប្រឡងចែកជាការប្រឡងទ្រឹស្តីនិងការប្រឡងអនុវត្តន៍(រួមទាំងការពិនិត្យសមត្ថភាពភាសាជប៉ុនដែលចាំបាច់ក្នុងការងារ) ហើយខ្លឹមសារសំណួរគឺមានដូចខាងក្រោម។ម្យ៉ាងទៀត រយៈពេលប្រឡងគឺ60នាទី ចំនួនសំណួរប្រឡងគឺប្រមាណ70សំណួរ(រួមទាំងសំណួរដែលមិនមែនសម្រាប់ដាក់ពិន្ទុគឺសម្រាប់ការវិភាគអត្រាឆ្លើយត្រូវជាដើម)។

（1）កសិកម្មដាំដំណាំទូទៅ

①ប្រឡងទ្រឹស្តី

・កសិកម្មដាំដំណាំទូទៅ

・សុវត្ថិភាពនិងអនាម័យ

・ពូជដំណាំនិងលក្ខណៈពិសេស

・បរិស្ថានដាំដុះ(អគារ បរិក្ខារ សម្ភារៈ ម៉ាស៊ីន)

・វិធីសាស្ត្រដាំដុះនិងការគ្រប់គ្រង

・ការកម្ចាត់ជំងឺនិងសត្វល្អិតចង្រៃ និងស្មៅចង្រៃ

・ការប្រមូលផល សម្របសម្រួល ស្តុកទុក បញ្ចេញលក់ ។ល។

②ប្រឡងអនុវត្តន៍(ទម្រង់វិនិច្ឆ័យដោយរូបគំនូស រូបថត(ទម្រង់CBT))

・ការសង្កេតមើលដី

・ការប្រើប្រាស់ជីនិងថ្នាំកសិកម្ម

・ការប្រើប្រាស់គ្រាប់ពូជ

・ការគ្រប់គ្រងបរិស្ថាន ការប្រើប្រាស់សម្ភារៈ បរិក្ខារនិងម៉ាស៊ីន

・ការងារពាក់ព័ន្ធនឹងការដាំដុះ

・សុវត្ថិភាពនិងអនាម័យ ។ល។

③ភាសាជប៉ុន

・ស្តាប់បានខ្លឹមសារជាដើមនៃការងារកសិកម្មដែលត្រូវបានណែនាំជាភាសាជប៉ុន

（2）កសិកម្មចិញ្ចឹមសត្វទូទៅ

①ប្រឡងទ្រឹស្តី

・កសិកម្មចិញ្ចឹមសត្វទូទៅ

・សុវត្ថិភាពនិងអនាម័យ

・ពូជសត្វ

・ការបង្កាត់ពូជនិងមុខងាររាងកាយ

・ការគ្រប់គ្រងការចិញ្ចឹម ។ល។

②ប្រឡងអនុវត្តន៍(ទម្រង់វិនិច្ឆ័យដោយរូបគំនូស រូបថត(ទម្រង់CBT))

・ការប៉ះពាល់និងទុកដាក់សត្វនិមួយៗ

・ការសង្កេតមើលសត្វនិមួយៗ

・ការគ្រប់គ្រងការចិញ្ចឹម ការប្រើប្រាស់ឧបករណ៍

・ការប៉ះពាល់និងទុកដាក់ផលិតផលដែលផលិតបាន

・សុវត្ថិភាពនិងអនាម័យ ។ល។

③ភាសាជប៉ុន

・ស្តាប់បានខ្លឹមសារជាដើមនៃការងារកសិកម្មដែលត្រូវបានណែនាំជាភាសាជប៉ុន

5 មូលដ្ឋានកំណត់ជាប់ធ្លាក់

ចំពោះពិន្ទុសរុប ត្រូវលើសពិន្ទុស្តង់ដារវិនិច្ឆ័យដែលសភាកសិកម្មជាតិកំណត់។

6 វិធានការបង្ការភាពមិនប្រក្រតីក្នុងការប្រឡង

ត្រូវអនុវត្តការប្រឡងឲ្យបានត្រឹមត្រូវតាមរយៈភ្នាក់ងារCBT ដោយចាត់តាំងចំនួនអនុរក្សប្រឡងឲ្យបានសមស្របទៅតាមទំហំនៃចំនួនបេក្ខជនប្រឡង។

ម្យ៉ាងទៀត ត្រូវបណ្តុះបណ្តាលអនុរក្សប្រឡងនិងចាត់វិធានការបង្ការភាពមិនប្រក្រតីដូចជា គ្រប់គ្រងសំណួរប្រឡងយ៉ាងតឹងរឹង បង្ការការបន្លំខ្លួនដោយបញ្ជាក់អត្តសញ្ញាណបេក្ខជនជាដើមតាមរយៈលិខិតឆ្លងដែនជាដើម ពិនិត្យវត្ថុយកចូលបន្ទប់ប្រឡង គ្រប់គ្រងឲ្យគ្រប់ជ្រុងជ្រោយនូវឧបករណ៍បញ្ជូនព័ត៌មានតាមខ្លួនដែលមានមុខងារបញ្ជូនព័ត៌មានដូចជាទូរស័ព្ទទំនើបស្មាតហ្វូនជាដើម។

7　វិធីប្រកាសជាសាធារណៈនូវលទ្ធផលប្រឡង

ទិន្នន័យលទ្ធផលប្រឡងដូចជា ខ្លឹមសារសង្ខេបនៃការអនុវត្តដែលរួមមានថ្ងៃអនុវត្តនិងទីកន្លែងអនុវត្តជាដើម ចំនួនបេក្ខជនប្រឡង អត្រាអ្នកឈានដល់ពិន្ទុស្តង់ដារជាដើម នឹងត្រូវប្រកាសជាសាធារណៈនៅលើគេហទំព័រដែលគ្រប់គ្រងដោយសភាកសិកម្មជាតិទៅតាមខែដែលអនុវត្តនិមួយៗ។

ម៉្យាងទៀត ក្រោយបញ្ចប់ឆ្នាំការងារនិមួយៗ ត្រូវដាក់របាយការណ៍ស្ថានភាពអនុវត្តការប្រឡង(ដោយរួមបញ្ចូលខ្លឹមសារប្រឡងដែលបានអនុវត្តនិងខ្លឹមសារសង្ខេបនៃលទ្ធផល)ទៅកាន់ក្រសួងយុត្តិធម៌មិនឲ្យមានការយឺតយ៉ាវ ហើយត្រូវទទួលការពិនិត្យពីក្រសួងយុត្តិធម៌ រួចប្រកាសជាសាធារណៈនូវរបាយការណ៍នោះ។

8　ចំណុចចាំបាច់ដទៃទៀត

（1）រយៈពេលសុពលភាពនៃរបាយការណ៍ពិន្ទុ

របាយការណ៍ពិន្ទុមានសុពលភាពរយៈពេល10ឆ្នាំគិតចាប់ពីថ្ងៃប្រឡង។ យ៉ាងណាមិញ រយៈពេលកំណត់នៃការរក្សាទុកទិន្នន័យលទ្ធផលប្រឡងនៅសភាកសិកម្មជាតិគឺ មានរយៈពេល5ឆ្នាំ។

（2）ការចេញរបាយការណ៍ពិន្ទុសាជាថ្មី

របាយការណ៍ពិន្ទុគឺអាចទទួលបានគ្រប់ពេលពីគេហទំព័រប្រឡងនៅក្នុងកំឡុង

ពេលរក្សាទុកទិន្នន័យលទ្ធផលប្រឡងដូចមានចែងក្នុងចំណុច8(1)ខាងលើ។

（3）ការការពារព័ត៌មានឯកជន

សភាកសិកម្មជាតិ ត្រូវប្រើប្រាស់ឲ្យបានត្រឹមត្រូវផ្អែកតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធចំពោះព័ត៌មានឯកជនដែលទទួលបាននៅក្នុងការបង្កើតនិងអនុវត្តការប្រឡងវាស់ស្ទង់សមត្ថភាពជំនាញកសិកម្ម។